# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ២៦៧ អក.មជ-៩៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោកព្រះរាជអាជ្ញាអមតុលាការ ខេត្តកោះកុង**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការជួញដូរមនុស្សទៅធ្វើពលកម្មយ៉ាងធ្ងន់ធ្ងរនៅប្រទេសថៃ ។
**យោង:** លិខិតលេខ ០១,៩៨ ចុះថ្ងៃទី១៥-០១-៩៨ របស់ការិយាល័យនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ។

ខ្ញុំសូមជម្រាបលោកថា ក្រសួងបានទទួលលិខិតដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើបញ្ជាក់ថានៅខេត្តកោះកុងមានអ្នកជួញដូរមនុស្សយកទៅធ្វើពលកម្មយ៉ាងធ្ងន់ធ្ងរនៅប្រទេសថៃ ហើយករណីនេះអង្គការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា សមាគមអាដហុកបានសរសេរលិខិតមកក្រសួងឱ្យជួយធ្វើអន្តរាគមន៍ទៅខេត្តកោះកុង ដើម្បីស្រាវជ្រាវរកមេខ្យល់ដែលដឹកនាំមនុស្សយកទៅធ្វើពលកម្មនៅប្រទេសថៃ ពីព្រោះអំពើនេះរំលោភទៅលើមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនិងមាត្រា ៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្សនិងអំពើធ្វើអាជីកម្មលើមនុស្ស ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦-០១-៩៦ ។

ខ្ញុំសូមឱ្យលោកព្រះរាជអាជ្ញា ដែលជាអ្នកទទួលខុសត្រូវលើដែនដីសមត្ថកិច្ចរបស់ខ្លួនអំពីសណ្តាប់ធ្នាប់សាធារណៈសន្តិសុខសង្គម និងការគោរពសិទ្ធមនុស្សនិងការគោរពច្បាប់ សូមលោកចាត់វិធានការជាបន្ទាន់ឱ្យនគរបាលយុត្តិធម៌ និងនគរបាលអន្តោប្រវេសន៍ខេត្តស្រាវជ្រាវរកឱ្យឃើញនូវមេខ្សែរយៈអ្នកដើរអូសទាញប្រមូលមនុស្សប្រុសស្រីចាស់ក្មេងយកទៅធ្វើពលកម្មនៅក្រៅ ជាពិសេសប្រទេសថៃចាប់បញ្ជូនទៅតុលាការផ្តន្ទាទោសឱ្យបានតឹងរ៉ឹងតាមច្បាប់និងតាមការណែនាំរបស់ក្រសួងយុត្តិធម៌ ។

ជូនភ្ជាប់មកជាមួយនូវសេចក្តីថតចម្លងលិខិតលេខ ០១៩៨ ចុះថ្ងៃទី១៥-០១-៩៨ របស់ការិយាល័យនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ១ច្បាប់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

ចម្លងជូន
-សាលាខេត្តកោះកុង
-តុលាការខេត្ត.ក្រុង
-លោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង
-ដើម្បីជ្រាប នឹងអនុវត្ត